# លោកឃួន វិចិត្រៈ ពីកម្មករោងចក្រម្នាក់ មកជា សហគ្រិនកសិកម្មវ័យក្មេងដ៏ជោគជ័យ

លោកឃួន វិចិត្រ គឺជាយុវជនម្នាក់ ដែលមានអាយុ ២៤ ឆ្នាំរស់នៅក្នុងភូមិមានជ័យ ស្រុកព្រៃវែង ខេត្តព្រៃវែង។ លោកបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី ១០ នៅឆ្នាំ ២០០១ ។ ក្រោយបញ្ចប់ការសិក្សា គាត់បានធ្វើការក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់អស់រយៈពេល ៤ ឆ្នាំកន្លះ។ គាត់បាននិយាយថា ដំបូងឡើយ គាត់អាចសន្សំប្រាក់បានចំនួន ៦០០ ដុល្លាក្នុងមួយឆ្នាំ និង ២០០ ដុល្លាសំរាប់ឆ្នាំទីពីរ ប៉ុន្តែនៅឆ្នាំទីបី និងទីបួន គាត់មិនអាចសន្សំបានឡើយ ដោយសារតែការចំណាយប្រចាំថ្ងៃរបស់គាត់ កាន់តែកើនឡើងដូចជា ថ្លៃម្ហូប និងថ្លៃឈ្នួលផ្សេងៗ។ល។ ដូចច្នេះការរស់នៅរបស់វិចិត្រ កាន់តែជួបការលំបាក។

នៅ ខែកក្កដា ឆ្នាំ ២០០៨ វិចិត្រ បានឮការផ្សព្វផ្សាយរបស់កម្មវិធី សហគ្រិនកសិកម្មវ័យក្មេងពីកម្មវិធីវិទ្យុ របស់អង្គការ សេដាក។ កម្មវិធីបានប្រកាសរកអ្នកស្ម័គ្រចិត្ត ដើម្បីចូលរួមនៅក្នុងកម្មវិធីនេះ។ គាត់បានដាក់ពាក្យរៀននៅក្នុងភូមិរបស់គាត់ស្ថិតនៅខេត្តព្រៃវែង។ ក្រោយពេលបានបំពេញការប្រលង ធ្វើតេស្ដិ៍ និងសម្ភាសន៏រួចមក លោកវិចិតត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងកម្មវិធីសហគ្រិនកសិកម្មវ័យក្មេង ហើយភ្លៀមៗនោះ គាត់បានឈប់ពីការងារនៅរោងចក្រ។

ចូលរួមជាមួយកម្មវិធី លោកវិចិត្របានទទួលយកនូវលំហាត់របស់គាត់សម្រាប់រយៈពេល ៦ ខែដំបូង។ ជាមួយនឹងលំហាត់នេះ គាត់បានធ្វើការសាកសួរ ទស្សនៈកិច្ច និងសង្កតមើល ព្រមទាំងសម្ភាសន៏ជាមួយ កសិករ ហើយនិងបានហាត់រៀនសរសេររបាយការណ៏ ក៏ដូចជាប្រវត្តផ្ទាល់ខ្លួនរបស់គាត់។ ដំបូងឡើយ គាត់មានការលំបាកក្នុងការធ្វើវា ប៉ុន្តែគាត់បានព្យាយាម ហើយនៅទីបំផុត គាត់ឈានដល់ដំណាក់កាល ជោគជ័យ។

ក្នុងអំឡុងពេល ៦ ខែលោកវិចិតរៀនចេះ ចំណេះដឹងបច្ចេកទេសកសិកម្មតាមគោលការណ៏ធម្មជាតិថ្មីៗ ជាច្រើន។ ចំណេះដឹងទាំងនោះរួមមានៈ

**១-ការធ្វើប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស):** គាត់បានចាប់ផ្តើមអនុវត្តនូវដំណាក់កាលខ្លះរបស់ប.វ.ស ដូចជាការដាំនូវសំណាបខ្ចី និងថ្លោសល្អ និងប្រើប្រាស់ពូជតិចជាងមុន ព្រមទាំងការស្ទូងជាជួរ ដោយប្រើជីកំប៉ុស្តិ៍ ជាដើម។ ជាមួយនឹងការអនុវត្តនេះ គាត់បានឃើញពីភាពខុសប្លែកគ្នានៃទិន្នផលស្រូវរបស់គាត់។ ក្នុងឆ្នាំ ២០០៧ គាត់ទទួលបានទិន្នផលត្រឹមតែ ២១៦០ គីឡូក្រាមក្នុងទំហំដី ១ ហិចតា ប៉ុន្តែក្នុងឆ្នាំ ២០០៨ ក្រោយពីការធ្វើតាមប.វ.ស ទិន្នផលស្រូវរបស់គាត់បានកើនឡើងទៅដល់ ៣៩៦០ គីឡូក្រាម។ ជាគ្នានោះដែរ ការប្រើប្រាស់វត្ថុធាតុដើមបានថយចុះ។

**២- ការប្រើប្រាស់ជីកំប៉ុស្តិ៍ក្នុងការដាំបន្លែ:** គាត់ធ្លាប់ដាំដុះបន្លែនៅលើផ្ទៃដី ៥០ ម៉ែត្រការ៉េ ដោយ ប្រើប្រាស់ជីគីមីនឹងថ្នាំពុលសំលាប់សត្វល្អិត ។ ការចំណាយលើសំភារៈទាំងនោះគឺអស់ ៨០ ០០០ រៀល ដោយមិនរាប់បញ្ចូលគ្រាប់ពូជនៅឡើយទេ ហើយដែលគាត់អាចរកចំណូលបាន ១២០ ០០០ រៀលពីការ ដាំដុះរបស់គាត់។ ដូចនេះគាត់ចំណេញបាន ៤០ ០០០ រៀល។ ក្រោយពីបានរៀនជាមួយកម្មវិធីរួចមក គាត់បានដាំបន្លែនៅលើដីទំហំដូចគ្នា ដោយមិនប្រើប្រាស់ជីគីមី និងថ្នាំពុលសំលាប់សត្វល្អិត។ ការចំណោយ របស់គាត់អស់ ១៤ ០០០ រៀលដោយរាប់ទាំងថ្លៃគ្រាប់ពូជ។ ហើយគាត់អាចលក់បាន ១៦០ ០០០ រៀល ពីផលិតផលពាក់កណ្តាលរបស់គាត់។ ភាពខុសខុសគ្នារវាងការដាំតាមទំលាប់ និងការដាំតាមរបៀបថ្មីនេះ គឺ គាត់ដាំចំរុះជាជាងការដាំតែមួយមុខ។ គាត់ដាំបន្លែដូចជាស្ពៃខៀវ អង្កាញ់ទឹក សណ្តែកគួ ត្រសក់ និងបន្លែសម្លផ្សេងៗទៀតនៅក្នុងសួនបន្លែរបស់គាត់។

**៣-ការចិញ្ចឹមត្រី:** គាត់ធ្លាប់ចិញ្ចឹមត្រីប្រាចំនួន ៣០០០ ក្បាល នៅក្នុងស្រះមានទំហំ ២៥ មនិង ៣០ ម។ គាត់ប្រើចំណីត្រី ដោយទិញមកពីផ្សារ។ ដូច្នេះនៅពេលដែលគាត់ចាប់ត្រី ក្រោយពេលដែលគាត់ចិញ្ចឹមបានរយៈពេល ៨ ខែ ឃើញថាគាត់នៅសល់ត្រីត្រឹមតែចំនួន ១៥០ ក្បាល។ ត្រីនីមួយៗមានទម្ងន់ ៤០០ ក្រាមជាមធ្យម ដូចនេះគាត់ត្រូវខាតបង់យ៉ាងច្រើនជាមួយនឹងការចិញ្ចឹមត្រីតាមទំលាប់នេះ។ ក្រោយពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីអំពីការចិញ្ចឹមត្រីពីកម្មវិធី គាត់បានទិញត្រីចំនួន ៧០០ ក្បាលទៅចិញ្ចឹម។ គាត់ចិញ្ចឹមទើបតែបានពីរខែ ត្រីមួយមានទំងន់ ២០០ ក្រាម ដោយគាត់តែឱ្យចំណី

ដែលអាចរកបានមកពីធនធាននៅតាមផ្ទះផ្ទាល់ដូចជា កន្ទក់ កាកសំណល់ពីសួនបន្លែ និងផ្ទះបាយជាដើម។ គាត់មានមោទនៈភាពជាខ្លាំង ដែលគាត់អាចរកវិធីចិញ្ចឹមបានល្អ។

**៤-ការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិៈ** គាត់ធ្លាប់ចិញ្ចឹមមាន់ចំនួនប្រមាណ ១០០ ក្បាល មុនពេលចូលរួមជាមួយកម្មវិធី ប៉ុន្តែមាន់របស់គាត់ទាំងអស់បានស្លាប់។ បន្ទាប់បានចូលរៀនរួចមក គាត់បានចាប់ផ្តើមចិញ្ចឹមម្តងទៀតដោយគ្មានការស្ទាក់ស្ទើរឡើយ។ គាត់បានទិញមេមាន់ចំនួន ១៥ ក្បាល ដើម្បីចិញ្ចឹម។ គាត់មិនចិញ្ចឹមតាមទំលាប់ទៀតទេ។ គាត់បានធ្វើទ្រុងមាន់ទំហំ ៥ ម៉ែត្រ គុណនឹង ៣ ម៉ែត្រ ជាមួយនឹងដំបូលទំហំ ១៥ ម៉ែត្រ គុណនឹង ២០ ម៉ែត្រ និងមានព័ទ្ធរបងឬស្សីជុំវិញ។ ពីរខែក្រោយមក មេមាន់ខ្លះបានចាប់ផ្តើមមានពង។

ឆ្លងកាត់កម្មវិធីយុវសហគ្រិនកសិកម្មវ័យក្មេង វិចិត្របានចូលរួមនៅក្នុងក្រុមសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯង។ ក្រុមនោះធ្វើការសន្សំលុយចំនួន ៥០០០ រៀលក្នុងមួយខែ ហើយវាបានកើនដល់ ១០ ០០០ រៀលក្នុងមួយខែ។ សរុបប្រាក់សន្សំបានទាំងអស់មានចំនួន ៧០ ពាន់រៀល។ ជាមួយការសន្សំរួមគ្នានេះ វិចិត្រ ក៏ដូចជាសមាជិកក្រុមផ្សេងទៀតអាចយកប្រាក់កម្ចីនេះ ដើម្បីធ្វើការបង្កើនការងារសិកម្ម និងរកស៊ីរបស់គេ ដើម្បីធ្វើអោយស្ថានភាពរស់នៅមានភាពប្រសើរឡើង។

បច្ចុប្បន្ន វិចិត្រមើលឃើញថា គ្រួសារគាត់បានរីរាយជាមួយនឹងជីវភាពរស់នៅប្រសើជាងមុន។ គាត់បានប្រាប់ប្រពន្ធគាត់អោយឈប់ធ្វើការនៅរោងចក្រ ដើម្បីមកជួយគាត់។ (ក្នុងអំឡុងពេល ៦ ខែខ្ញុំអាចរកបានប្រមាណ ៥០០ ដុល្លាពីអ្វីដែលខ្ញុំធ្វើដូចជា ប.វ.ស និងការដាំបន្លែ) គាតនិនាយ។ នេះមិនរាប់បញ្ចូលទាំងការប្រើប្រាស់នឹងការបរិភោគរបស់គ្រួសាគាត់ទេ។

ឥឡូវគាត់មានបំណងចង់ពង្រីកកសិដ្ឋានពហុប្រយោជន៏របស់គាត់នៅលើដីស្រែកន្លះហិចតារបស់គាត់។ គាត់បានជីកប្រឡាយមួយនៅជុំវិញស្រែរបស់គាត់។ គាត់គ្រោង ចិញ្ចឹមត្រីនៅក្នុងស្រែ និងធ្វើប.វ.ស នៅលើដីស្រែទាំងអស់របស់គាត់។ វិចិត្រសង្ឃឹមថា ប្រាក់ចំណូលរបស់គាត់នឹងអាចកើនដល់ ២០០០ ដុល្លា ក្នុងឆ្នាំ ២០០៩ និង ៧ ទៅ ៨ ពាន់ដុល្លាក្នុងអំឡុងប្រាំឆ្នាំក្រោយ។ ជាលទ្ធផលរបស់កម្មវិធីនិងការអនុវត្ត

ផ្ទាល់លើដីស្រែរបស់គាត់ បច្ចុប្បន្នមានអ្នកជិតខាង ដែលជាកសិករ បានសុំអោយគាត់ជួយបង្រៀនពួកគាត់អំពីបច្ចេកទេសថ្មីនេះ។

គួរកត់សំគាល់ថា សេដាកសហការជាមួយអង្គការ សាក្រិតនៅក្នុងខេត្តព្រៃវែង បានអនុវត្តគំរោងមួយដែលមានឈ្មោះថា សហគ្រិនកសិកម្មវ័យក្មេងចាប់ពីខែកក្កដា ឆ្នាំ ២០០៨ ដល់ខែមិថុនា ឆ្នាំ ២០១០។ គំរោងនេះទទួលបានការឧត្ថម្ភថវិកាដោយអង្គការ ហេកស។ គោលបំនងរបស់កម្មវិធីនេះគឺដើម្បីកសាងសមត្ថភាពយុវជនជនបទក្នុងការចាប់យកមុខចំនាញកសិកម្ម និងដើរតួនាទីយ៉ាងសំខាន់ក្នុងការងារអភិវឌ្ឍន៍ជនបទ។

